| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | សិក្សាសង្គម |
| **ប្រធានបទ** | ចម្រៀង និងតន្ត្រី |
| **ចំណងជើងមេរៀន** | ល្បែងទះដៃឬគោះសម្ភារតាមចង្វាក់ ដកស្រង់ចេញពី<br>" រឿង តើអ្នកពូកែអី?" ។ |
| **កម្រិត** | ទាប ៣០នាទី |
| **គោលបំណង** | -ឱ្យកុមារសម្តែងចេញតាមរយៈបទពិសោធនៃការច្រៀង។<br>-កុមារបង្ហាញចំណេះដឹងពីបច្ចេកទេសនានានៃតន្ត្រី។<br>-កុមារសម្តែងចលនាច្នៃប្រឌិត និងបទពិសោធផ្នែករបាំ។ |
| **បំណិនសម្បទា** | ច្រៀងចម្រៀង និងធ្វើកាយវិការត្រូវតាមខ្លឹមសារ<br>បទចម្រៀង។ |
| **ចរិយាសម្បទា** | សប្បាយរីករាយ សហការគ្នា និងស្រឡាញ់<br>ចូលចិត្តបទចម្រៀង។ |
| **គ្រូបង្រៀន (ផលិតសម្ភារឧបទេស)** | ប្រមូលត្រឡោកដូង ហើយពុសជាពីរចំណែក។ |
| **កុមារ** | ទះដៃបន្ទរ ឬគោះតាមចង្វាក់ភ្លេង និងធ្វើកាយវិការ។ |
| **ការរៀបចំ** | រៀបចំកន្លែងសម្រាប់ក្មេង បែងចែកកុមារតាមក្រុម។ |

| **សកម្មភាពគ្រូបង្រៀន** | **មាតិកា** | **សកម្មភាពសិស្ស** |
|---|---|---|
| ១. ណែនាំពាក្យ "ចង្វាក់" ។<br>២. ឱ្យកុមារៗថាតាមពាក្យនេះ។<br>៣.សួរកុមារថាតើស្គាល់ពាក្យនេះ<br>ដែរឬទេ។<br>៤. ពន្យល់និយមន័យនៃពាក្យ ចង្វាក់<br>នេះ។<br>៥. ផ្តល់ជាឧទាហរណ៍ដល់សិស្ស<br>(ឧទាហរណ៍៖បទចម្រៀងមួយ<br>ដែលអ្នកច្រៀងលឿន និងយឺត ដូចជាបទ | និយមន័យ៖ លំអានដដែលៗនៃ<br>សម្លេង។ ដូចជាលំអានពណ៌ ក្រហម<br>ក្រហម បៃតង ក្រហម ក្រហម បៃតង។ | ១. ចូរស្តាប់គ្រូបង្រៀន។<br>២. ចូរថាតាមពាក្យ "ចង្វាក់" ។<br>៣. ចូរឆ្លើយសំណួរ ប្រសិនបើអ្នកដឹងពីនិ<br>យមន័យរបស់ពាក្យនេះ។<br>៤. ចូរស្តាប់អ្នកគ្រូ/លោកគ្រូ<br>៥. ចូរគោះតាមចង្វាក់ភ្លេងនៃឈ្មោះគ្រូរប<br>ស់អ្នក។<br>៦. ចូរជ្រើសរើសឈ្មោះមិត្តរួមថ្នាក់របស់អ្នក<br>ប្រសិនបើអ្នកគ្រូ/លោកគ្រូសួរ។ |

| | | |
|---|---|---|
| អាក់ប់ពីយ៉ាពេល<br>ច្រៀងលឿន ត្រូវទះដៃលឿន<br>តាមចង្វាក់ បើយឺតគឺត្រូវយឺត<br>តាមចង្វាក់ដែរ) ។<br>៦. ទះដៃតាមចង្វាក់នៃឈ្មោះ<br>របស់អ្នក។<br>៧. ឱ្យកុមារៗទះដៃតាមចង្វាក់<br>នៃឈ្មោះរបស់អ្នក។<br>៨. បែងចែកកុមារជាគូៗ (ប្រសិនបើចំនួ<br>នកុមារជាចំនួនសេស អ្នកអាចជាដៃគូរប<br>ស់កុមារម្នាក់នោះ)<br>៩. ផ្ដល់ត្រឡោកដូងមួយគូដល់ដៃគូនីមួ<br>យៗ (មួយចំហៀង<br>សម្រាប់កុមារម្នាក់) ។<br>១០. ឱ្យកុមារម្នាក់ប្រាប់ឈ្មោះ<br>មិត្តរួមថ្នាក់ម្នាក់របស់ពួកគេ។<br>១១. អានតាមឈ្មោះនោះយឺតៗ<br>គោះត្រឡោកដូងមួយគូលើគ្នា។<br>១២. ឱ្យកុមារៗធ្វើតាម។<br>១៣. កុមារ ត្រូវធ្វើការជាមួយ<br>គ្នា “គោះ”<br>ត្រឡោកតាមចង្វាក់ឈ្មោះ<br>ស្របពេលនិយាយ<br>ឈ្មោះលឺៗ។<br>១៤. ឱ្យពួកគេហ្វឹកហាត់និយាយឈ្មោះ<br>និងគោះត្រឡោកដដែលៗជាច្រើនដងយឺ<br>តៗ រហូតពួកគេអាចធ្វើការជាមួយគ្នាបា<br>ន។<br>១៥. គោះតាមចង្វាក់ ៣ ឬ ៤ដង<br>ទៅតាមចង្វាក់ឈ្មោះ រតនា<br>(រត្ន័ តា ណា...) ។<br>១៦. ឱ្យកុមារធ្វើតាម។<br>១៧. កុមារម្នាក់ទៀតជ្រើសរើសឈ្មោះមិ<br>ត្តរួមថ្នាក់។<br>១៨. ប្រសិនបើកុមារអាចធ្វើ | | ៧. ចូរកាន់ត្រឡោកដូងនៅដៃ<br>ដែលអ្នកចង់កាន់ ហើយបែរមុខទៅដៃគូរប<br>ស់អ្នក។<br>៨. ចូរធ្វើការជាមួយគ្នាធ្វើយ៉ាងណាឱ្យត្រ<br>ឡោកដូងទាំងពីរ<br>ចំហៀងជួបគ្នា។<br>៩. ចូរមើលត្រឡោកដូងរបស់ដៃ<br>គូអ្នក។<br>១០. គោះត្រឡោកដូងតាមឈ្មោះ<br>ស្របពេលដែលអ្នកនិយាយឈ្មោះលឺៗ។ |

| | | |
|---|---|---|
| សកម្មភាពនេះបានព្យាយាមផ្គុំឈ្មោះ២ក្នុងពេលតែមួយ<br>(ឧទាហរណ៍៖ រតនា អារុណា) ។ | | |